# សុន្ទរកថាបើក

## របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## និង ជាសហប្រធាននៃកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី ២

- ***ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និង ជាសហប្រធាននៃកិច្ចប្រជុំ;***
- ***ឯកឧត្តមប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសទន្លេមេគង្គ;***
- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ជាទីមេត្រី !***

ជាបឋម, តាងនាមឱ្យរាជរដ្ឋាភិបាល និង ប្រជាជនកម្ពុជា, ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះឯកឧត្តម, លោកជំទាវគ្រប់រូប, ដែលអញ្ជើញមកដល់រាជធានីភ្នំពេញ ដើម្បីចូលរួមកិច្ចប្រជុំកំពូលមេគង្គ-ឡានឆាង លើកទី ២ ។ ខ្ញុំចាំបានថា នៅពេលយើងជួបគ្នានៅក្នុងកិច្ចប្រជុំកំពូលលើកទី ១ នៅសានយ៉ា (Sanya) ខ្ញុំបានលើកឡើងថា ពាក្យ «**សានយ៉ា**» ស្រដៀងទៅនឹងពាក្យខ្មែរថា «**សន្យា**» ។ ក្នុងន័យនេះ, យើងអាចនិយាយដោយប្រៀបធៀបបានថា **«សេចក្តីថ្លែងការណ៍សានយ៉ា»** ជាការសន្យាជឧឡារិកមួយដោយប្រទេសទាំង ៦ នៃទន្លេមេគង្គថា នឹងខិតខំធ្វើឱ្យយន្តការអនុតំបន់ដែលទើបនឹងកើតមកថ្មីនេះ អាចក្លាយទៅជាគម្រោងកិច្ចសហប្រតិបត្តិការពេញលេញ និង នាំមកនូវសន្តិភាព, សន្តិសុខ, កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង វិបុលភាព សម្រាប់តំបន់របស់យើង ។ ថ្ងៃនេះ, យើងអាចយល់ស្របទាំងអស់គ្នាថា **«ការសន្យាសានយ៉ា»** នេះ ត្រូវបានរក្សាយ៉ាងហ្មត់ចត់ ។

ខណៈនេះ, យើងកំពុងជួបគ្នានៅរាជធានីភ្នំពេញ ដែលមានទន្លេមេគង្គហូរឆ្លងកាត់, យើងអាចមើលឃើញ និង វាយតម្លៃខ្ពស់ចំពោះកម្លាំង និង អំណាចដ៏មហិមានៃទន្លេនេះ ក្នុងការជួយគាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋរាប់លាននាក់ រស់នៅតាមបណ្តោយនៃដងទន្លេនេះ ។ ពិតណាស់, តាមលក្ខណៈភូមិសាស្ត្រ, ទន្លេនេះ បានភ្ជាប់ប្រទេសរបស់យើងជាមួយគ្នា; ប៉ុន្តែ ជាក់ស្តែងលើសពីការតភ្ជាប់ជារូបវន្ត, ទន្លេនេះ បានជំរុញយើងឱ្យបង្កើតវាសនារួមគ្នាប្រកបដោយមិត្តភាព, ភាពជាអ្នកជិតខាងល្អ, សន្តិភាព និង វិបុលភាព ។ ស្មារតីនេះ បានជំរុញលើកទឹកចិត្តយើងទាំងអស់គ្នាឱ្យប្រើប្រាស់ថាមពលនេះ ដើម្បីប្រែក្លាយ **«ការសន្យាសានយ៉ា»** ឱ្យទៅជាការពិត ។ ហេតុនេះ, កម្ពុជាមានមោទនភាព និង ពិតជាមានកិត្តិយស ក្នុងការទទួលរៀបចំកិច្ចប្រជុំនៅពេលដ៏សំខាន់មួយនេះ ដែលយើងនឹងផ្លាស់ប្តូរពីដំណាក់កាលចាប់ផ្តើមបីបាច់ថែរក្សា ទៅជា **«ដំណាក់កាលរីកលូតលាស់»** ដែលត្រូវបានកំណត់ដោយរបៀបវារៈប្រកបដោយមហិច្ឆតានៃភាពជាដៃគូ និង កិច្ចសហប្រតិបត្តិការ ។

***ឯកឧត្តមសហប្រធាន, ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី !***

សម្រាប់កម្ពុជា, កិច្ចប្រជុំថ្នាក់ដឹកនាំលើកទី ២ នេះ មានន័យជ្រាលជ្រៅណាស់ ហើយមិនមែន ជារឿងចៃដន្យនោះទេ ដែលយើងបានជ្រើសរើសយកប្រធានបទ «**ទន្លេរបស់យើង: ដើម្បីសន្តិភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព**» ។ **សន្តិភាពប្រកបដោយនិរន្តរភាព និង ការអភិវឌ្ឍប្រកបដោយចីរភាពយូរអង្វែង**

ត្រូវតែអត្ថិភាព និង ដំណើរទៅមុខជាមួយគ្នា ។ យើងមិនអាចមើលរំលងចំណុចទាំងពីរនេះបានទេ ។ ក្នុងពេលដែលភាពមិនច្បាស់លាស់ក្នុងតំបន់ និង ពិភពលោក កំពុងផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស, ទាំងផ្នែកនយោបាយ និង សេដ្ឋកិច, តំបន់មេគង្គរបស់យើង នឹងក្លាយជាតំបន់ដែលនឹងត្រូវឆ្លងកាត់ការសាកល្បងជាថ្មីម្ដងទៀត ។ យើងមិនត្រូវភ្លេចទេថា នៅក្នុងប្រវត្តិសាស្ត្រកន្លងផុតទៅមិយូរប៉ុន្មាន, តំបន់របស់យើងត្រូវបានបំផ្លិចបំផ្លាញខេចខ្ទាំ ដោយ-សារសង្គ្រាម និង ការប្រកួតប្រជែងនៃមនោគមវិជ្ជា ។ សម្រាប់កម្ពុជា, ខ្ញុំផ្ទាល់នៅតែមានការចងចាំដ៏ជូរចត់អំពីការជ្រៀតជ្រែកពីខាងក្រៅ ដែលបណ្ដាលឱ្យមានចលាចល និង ភាពវឹកវរ ដែលបានបំផ្លាញសន្តិភាព និង ស្ថិរភាពរបស់យើង ហើយបានរារាំងដល់កំណើនសេដ្ឋកិចរបស់យើងអស់ពេលជាច្រើនទសវត្ស ។

បទពិសោធន៍នៃតំបន់របស់យើង បានបញ្ជាក់ប្រាប់យើងច្បាស់ថា យើងអាចសម្រេចបាននូវសន្តិភាពពេញលេញ តាមរយៈការគោរពគ្នាទៅវិញទៅមក ចំពោះបូរណភាពដែនដី និង អធិបតេយ្យភាពរបស់ផងគ្នា ហើយមិនជ្រៀតជ្រែកកិចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក ។ ចំណុចនេះពិតជាមានសង្គតិភាពជាមួយតម្លៃនៃកិចសហប្រតិ-បត្តិការមេគង្គ-ឡានឆាង ដែលប្រកាន់ខ្ជាប់នូវគោលការណ៍នៃមតិឯកច្ឆន្ទ, សមភាព, ការពិគ្រោះយោបល់ និង ការសម្របសម្រួលគ្នាទៅវិញទៅមក, ការស្ម័គ្រចិត្ត, ការចូលរួមជាមួយគ្នា និង ផលប្រយោជន៍រួម ព្រមទាំងការគោរពចំពោះធម្មនុញ្ញអង្គការសហប្រជាជាតិ និង ច្បាប់អន្តរជាតិ ។ គុណតម្លៃទាំងនេះ បានចូលរួមកសាងតំបន់របស់យើង បានយ៉ាងល្អកងបំណងប្រាថាសែងរក «**សន្តិភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព**» ។

***ឯកឧត្តមសហប្រធាន, ឯកឧត្តម, លោកជំទាវ, អស់លោក, លោកស្រី !***

ខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នាពេញចិត្តនឹងការតាំងពិព័រណ៍ស្ដីពីសមិទ្ធផលជាក់ស្ដែងនៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ។ ខ្ញុំពិតជាស្ងើចសរសើរចំពោះល្បឿន និងវឌ្ឍនភាពនៃការអភិវឌ្ឍកិចសហប្រតិបត្តិការមេគង្គ-ឡានឆាងរបស់យើង ។ ទន្ទឹមនេះដែរ, ខ្ញុំសូមកត់សម្គាល់ដោយពេញចិត្តថា នៅក្នុងកិចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ឡានឆាង លើកទី ៣ ដែលត្រូវបានរៀបចំកាលពីខែមុននៅ **ទីក្រុងតាលី** គម្រោងចំនួន ១៣២ ត្រូវបានអនុម័តជាគម្រោងដំណាក់កាលទី ១ គាំទ្រដោយមូលនិធិពិសេសនៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ ២០១៧ និង បញ្ជីគម្រោងផ្សេងទៀតនៃមូលនិធិពិសេសកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលមានគម្រោងចំនួន ២១៥ កំពុងត្រូវបានដាក់ស្នើសម្រាប់ការវាយតម្លៃ ។ ច្បាស់ណាស់ថា នេះ គឺជាលក្ខណៈពិសេសជាក់ស្ដែងមួយរបស់កិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដែលជា **យន្តការផ្អែកលើគម្រោង/កិចសហប្រតិបត្តិការ** ហើយមិនមែនគ្រាន់តែជា **វេទិកាពិភាក្សានោះទេ** ។

រហូតមកដល់ពេលនេះ យើងបានពូតផ្គុំឆន្ទៈនយោបាយរបស់យើង, យើងបានរួមបញ្ចូលកម្លាំងសេដ្ឋកិចរបស់យើង, យើងបានទាញយកផលប្រយោជន៍ពីតំបន់របស់យើង ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រទេសរបស់យើងរៀងៗខ្លួន និង ពង្រឹងកំណើននៃអនុតំបន់របស់យើង ក្នុងស្មារតីនៃមាគ៌ាកិចសហប្រតិបត្តិការមេគង្គ-ឡានឆាងរបស់យើង ដែលស្របទៅនឹងមាគ៌ាអាស៊ានដ៏ល្បីល្បាញរបស់យើង ។ យើងបានរកឃើញនូវវិធីសាស្ត្ររួម ដែលឆ្លុះបញ្ចាំងពីផ្នែកសំខាន់ ៣ នៃកិចសហប្រតិបត្តិការមេគង្គ-ឡានឆាង ស្របជាមួយសសរស្ដម្ភចំនួន ៣ របស់សហ-គមន៍អាស៊ាន ។ នោះហើយជាមូលហេតុជំរុញឱ្យយើងសម្រេចបានយ៉ាងលឿន នូវការបង្កើតយន្តការកិចសហ-

ប្រតិបត្តិការមេគង្គ- ឡានឆាង ដែលដើរតួយ៉ាងសំខាន់កងការគាំទ្រផលប្រយោជនរបស់បណ្តាប្រទេសទន្លេមេគង្គ ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចអាស៊ាន ជាពិសេសជាមួយប្រទេសចិន ដែលជាអ្នកគាំទ្រយ៉ាងខ្លាំងដល់ការធ្វេសមាហរណកម្មអាសាន និង កិច្ចសហប្រតិបត្តិការពហុភាគីសកលលោក ។

ជាមួយនឹងជំនឿដ៏រឹងមាំនេះ, ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំថ្នាក់ដឹកនាំកិច្ចសហប្រតិបត្តិការមេគង្គ- ឡាន-ឆាង លើកទី ២ ហើយខ្ញុំរង់ចាំការចូលរួមចំណែកដ៏សកម្មរបស់ឯកឧត្តមគ្រប់រូប ដើម្បីធានាឱ្យបាននូវជោគជ័យនៃកិច្ចប្រជុំរបស់យើងនាថ្ងៃនេះ ។ សូមអរគុណ !

****+****